# កម្មវិធីគាំទ្រសេវាអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល

# (អេស្កាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

# វគ្គតំរង់ទិសស្តីពីការកំណត់កុមារដែលមិនបានចូលរៀន

## សម្រាប់

## គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ

## និង នាយកសាលា




# ការចូលរួមរបស់គណៈកម្មាធិការមូលដ្ឋាន

# រួមចំណែកលើកកំពស់បរិយាកាសសិក្សាតាមបែបកុមារមេត្រី

# មាតិកា


| លរ. | ខ្លឹមសារ | រយៈពេល |
|---|---|---|
| | *I. ថ្ងៃទី១ ៖* | |
| **1** | **ការផ្ដើមសិក្ខាសាលា** | |
| 1.1 | ការណែនាំឱ្យស្គាល់គ្នា | 20 នាទី |
| 1.2 | គោលបំណងសិក្ខាសាលា | 10 នាទី |
| **2** | **សិទ្ធិកុមារ** | 45 នាទី |
| **3** | **ការអប់រំសម្រាប់ទាំងអស់គ្នា** | |
| 3.1 | ការពុះពារដើម្បីសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា | 30 នាទី |
| 3.2 | បញ្ញត្តិ ស្ដីអំពីអ្នកពាក់ព័ន្ធ និងការចូលរួមរបស់អ្នកពាក់ព័ន្ធ | 45 នាទី |
| 4 | **ការវិភាគនិងដោះស្រាយបញ្ហាបញ្ហា** | |
| 4.1 | ការកំណត់បញ្ហា: ហេតុអ្វីកុមារមិនបានចូលរៀន? | 45 នាទី |
| 4.2 | តើអេស្កាប់ជាអ្វី ហើយអេស្កាប់ជួយដោះស្រាយបញ្ហាទាំងនេះ ដូចម្ដេចខ្លះ? | 10 នាទី |
| 4.3 | វិធី ក្នុងការកំណត់កុមារដែលមិនបានចូលរៀន | 20 នាទី |
| **5.** | **ការគូរផែនទីសាលារៀន** | |
| 5.1 | ការកំណត់ព័ត៌មាននិងចំណុចសំខាន់ៗព្រមទាំងនិមិត្តសញ្ញា សម្រាប់បង្ហាញនៅក្នុងផែនទី | 30 នាទី |
| 5.2 | ការគូរផែនទីតាមភូមិ | 60 នាទី |
| 5.3 | ការបង្ហាញលទ្ធផលក្នុងក្រុមធំ | 30 នាទី |
| **6** | **សកម្មភាពក្នុងជំហានបន្ទាប់** | 15 នាទី |
| | ***ថ្ងៃទី២**** | |
| 6.1 | ការសង្ខេបមេរៀនថ្ងៃទី១ | 10 នាទី |
| 6.2. | ការបង្ហាញព័ត៌មានដែលប្រមូលបានតាមភូមិនិមួយៗ | 30 នាទី |
| 6.3 | ការរំលឹកឡើងវិញអំពីនិមិត្តសញ្ញាដែលបានកំនត់ | 15 នាទី |
| 6.4 | ការគូរផែនទីបង្ហើយ និងបញ្ចប់ | 60 នាទី |
| 6.5 | ការបង្ហាញផែនទីភូមិ តាមភូមិនិមួយៗ | 30 នាទី |
| 7 | **សកម្មភាពតាមដាន ក្នុងជំហានបន្ទាប់** | |

| | | |
|---|---|---|
| 7.1 | ការបែងចែកការងារ ក្នុងការចុះតាមដាន | 45 នាទី |
| 7.2 | ការឯកភាពគ្នាលើការងារដែលបានបែងចែក | 10 នាទី |
| 7.3 | ការបិទសិក្ខាសាលា | 10 នាទី |

សំគាល់:

ព្រឹក: 7:30-11:00

ល្ងាច: 1:30 – 4:30

សម្រាក: កន្លះម៉ោង

* សិក្ខាសាលានេះ ដំណើរការពីរលើក: លើកទី១ មានរយ:ពេលពេញមួយថ្ងៃ និងលើកទី២មានយរយ:ពេលកន្លះថ្ងៃ។ នៅចន្លោះសិក្ខាសាលាទាំងពីរ មានការចុះសស្រង់ព័តិមានតាមផ្ទះ ។

# ការកំណត់កុមារដែលមិនចុះឈ្មោះចូលរៀន

## I. សេចក្តីផ្តើម :

### ក- ការពុះពារដើម្បីសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា

ចាប់តាំងពីមានសន្និសិទ្ធអន្តរជាតិ ស្តីអំពីការអប់រំសម្រាប់ទាំងអស់គ្នានៅជំទៀមនិងថ្មីៗនេះនៅទីក្រុងដាកា ដែលមាន១១៦ ប្រទេសបានចូលរួម រួមទាំងប្រទេសកម្ពុជាផងនោះ បានសន្យាថាកុមារគ្រប់រូបនឹងត្រូវបាន ទទួលការអប់រំជាមូលដ្ឋាន ប្រកបដោយគុណភាពនៅឆ្នាំ២០១៥។ អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានរួមចំនែក យ៉ាងខ្លាំងក្លាក្នុងការធានាអោយកុមារកម្ពុជាមានសិទ្ធិទទួលការអប់រំពេញលេញ និងធ្វើអោយសម្រេចគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា។ ទោះយ៉ាងនេះក្តី នៅតែមានគំលាតគួរអោយកត់សំគាល់រវាងគោលនយោបាយអប់រំនិងការអនុវត្តជាក់ស្តែង។ កត្តាចំនងៗមួយចំនួន ទាំងកត្តាផ្គត់ផ្គង់និងកត្តាតំរូវការ នៅបន្តធ្វើអោយរាំងស្ទះដល់គុណភាពអប់រំទូទាំងប្រទេស ជាពិសេសនៅតំបន់ដាច់ស្រយាល រួមមានកង្វះគ្រូ កម្មវិធីសិក្សាមិនទាន់ឆ្លើយតបទៅនឹងការរស់នៅជាក់ស្តែងពេញលេញ ភាពងាយស្រួលក្នុងការចូលរៀននៅមានកំរិត ដោយសារការចំណាយផ្ទាល់ និងមិនផ្ទាល់របស់មាតាបិតា លើការសិក្សារបស់កូន និងការយល់ឃើញរបស់ សហគមន៍ដែលមិនទាន់អោយតំលៃខ្ពស់លើការអប់រំ។

### ខ- សេចក្តីត្រូវការ ការចូលរួមរបស់សហគមន៍

ការតាំងចិត្តនិងការចូលរួមរបស់សហគមន៍មានសារៈសំខាន់ណាស់ ក្នុងការធ្វើអោយកុមារទាំងអស់ទទួលបានការអប់រំដែលមានគុណភាព។ រដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលតែឯកឯងមិនអាចផ្តល់ធនធានដែល ត្រូវការនោះបានគ្រប់គ្រាន់ទេ គឺមានតែសហគមន៍ខ្លួនឯងប៉ុណ្ណោះ ដែលអាចចលនាបំផុសរកនិងផ្តល់ធនធានមនុស្ស សម្ភារ និងធនធានផ្សេងៗទៀតបាន។ សហគមន៍ក៏អាចប្រមូលផ្តុំនិងនាំមកនូវលំនាំបែបបទការងារផ្សេងៗជាច្រើនទៀត ដែលអាចធ្វើអោយការប្រតិបត្តិការងារ នៅមូលដ្ឋានមានដំណើរការស៊ីសង្វាក់គ្នាទៅនឹង គោលនយោបាយថ្នាក់ជាតិ ។ និយាយរួម បើគ្មានការគាំទ្រ និងភាពជាម្ចាស់របស់សហគមន៍នោះការងារទាំងឡាយ ពិតជាពុំអាចមាននិរន្តរភាពបានឡើយ។

### គ- តើអ្វីទៅជាកម្មវិធីអេស្កាប់ ហើយអេស្កាប់អាចជួយដូចម្តេចដើម្បីឆ្លើយតបនឹងការពុះពារទាំងនេះ?

កម្មវិធីអេស្កាប់ គឺជាការផ្តួចផ្តើមដែលរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងឡាយ ដែលបានរៀប រាប់ខាងលើក្នុងគោលបំណងបង្កើនភាពងាយស្រួលក្នុងការចូលរៀនប្រកបដោយគុណភាព សំរាប់កុមារដែលទទួល សេវាអប់រំមិនគ្រប់គ្រាន់។ កម្មវិធីនេះ ទទួលថវិកាពីវិទ្យាស្ថានស្រាវជ្រាវអាមេរិក ហៅកាត់ថាអេ អាយ អ (AIR) និងកម្មវិធីកែលំអគុណភាពអប់រំ (EQUIP1) ក្រោមកិច្ចព្រមព្រៀងសហការ ជាមួយភ្នាក់ងារអភិវឌ្ឍអន្តរជាតិ សហរដ្ឋអាមេរិក(USAID)។ កម្មវិធីអេស្កាប់ ផ្តោតទៅលើសមាសភាគធំៗបី រួមមានការបំប៉នគ្រូ ភាពងាយស្រួល ក្នុងការចូលរៀនប្រកបដោយគុណភាព និងភាពជាដៃគូរវាង សាលារៀន និងសហគមន៍។កម្មវិធី ក៏ផ្តោតជាសំខាន់ ទៅលើការពង្រឹងការយល់ដឹង ជំនាញ បទពិសោធន៍និងអភិវឌ្ឍឥរិយាបទរបស់ដៃគូ ក្នុងការធ្វើឱ្យបញ្ញត្តិសាលា កុមារមេត្រី ក្លាយទៅជាការអនុវត្តជាក់ស្តែង។

## II. ការកំនត់កុមារដែលមិនបានចុះឈ្មោះចូលរៀន

កុមារជាច្រើននាក់ មិនបានចុះឈ្មោះចូលរៀននៅក្នុងសាលាបឋមសិក្សា។ នេះគឺជាបញ្ហា របស់កុមារដែលងាយរងគ្រោះ រួមមាន កុមារកំព្រា កុមារពិការ និងកុមារដែលមានគ្រួសារក្រីក្រ។ អង្គការខេប បានព្យាយាមដោះស្រាយបញ្ហាទាំងនេះតាមរយៈការធ្វើអន្តរាគមន៏ ដោយផ្តល់ជូនកុមារនូវអាហារូបករណ៏ និងកម្មវិធីគេហកិច្ចសំរាប់កុមារនៅថ្នាក់ទី៥ និងថ្នាក់ទី៦។ ទោះបីជាយ៉ាងនេះក៏ដោយ សាលារៀនត្រូវតែធ្វើការកំណត់សិស្សអោយបានច្បាស់លាស់ អំពីចំនួនកុមារដែលមិនបានចុះឈ្មោះចូលរៀននៅបឋមសិក្សា។ ឯកសារនេះពន្យល់ដល់អ្នកគ្រប់គ្រងសាលារៀន, បុគ្គលិកសិក្សា, សហគមន៏ និង សិស្សថ្នាក់ទី ៥-៦ ធ្វើការសហការគ្នាដើម្បីកំណត់កុមារដែលមានសេចក្តីប្រថុយនៅក្នុងមូលដ្ឋានរបស់គេនិងរបៀបតាមដាន ទៅលើបញ្ហាទាំងនោះ។

## III. គោលបំណង

- អ្នកគ្រប់គ្រងសាលារៀន, បុកគ្គលិកសាលា, សហគមន៏ និង សិស្សថ្នាក់ទិ៥-៦ កំណត់កុមារ ដែលប្រថុយមិនបាន ចុះឈ្មោះចូលរៀននៅក្នុងមូលដ្ឋានរបស់គេ ។
- អ្នកគ្រប់គ្រងសាលារៀន, បុគ្គលិកសាលាតាមដាននិងធ្វើអន្តរាគមន៏កុមារដែលដល់អាយុមិនចុះឈ្មោះចូលរៀន នៅតាមមូលដ្ឋានរបស់គេ។

## IV. រយះពេល

- ការរៀបចំប្រជុំជាមួយអ្នកគ្រប់គ្រងសាលារៀន, បុគ្គលិកសាលា, មេភូមិ និងតំណាងក្រុមប្រឹក្សាឃុំ ចំណាយពេលកន្លះថ្ងៃ។
- មេរៀនស្តីពីការប្រើប្រាស់ទម្រង់ស្រាវជ្រាវដែលអនុវត្តដោយសិស្សថ្នាក់ទី៥-៦ ចំណាយពេលកន្លះថ្ងៃ។
- បន្ទាប់ពីការស្រាវជ្រាវ ត្រូវរៀបចំការប្រជុំកន្លះថ្ងៃទៀតដើម្បីវិភាគលើផែនទីអំពីទីតាំងដែលបង្ហាញពីកុមារដែលមានសេចក្តីប្រថុយមិនបានចុះឈ្មោះចូលរៀន។

## V. សំភារះ

១- ក្រដាសផ្ទាំងធំ កន្លះគីឡូ

២- ហ្វឹតពិណក្រហម និង ខៀវ ៦ ដើម

៣-ក្រដាស A 4 កន្លះគីឡូ

៤-ក្រដាសរាមពិណ ៤0 សន្លឹក

៥-ក្រដាសកាតុង ៣ សន្លឹក

៦-ស្កុតក្រដាស ១ ដុំ

៧-ឯកសារឧបសម្ពន្ធ A : ផែនការបង្រៀនស្តីពីការប្រើប្រាស់ឧបករណ៏ស្រាវជ្រាវសំរាប់គ្រូ-ថ្នាក់ទី ៥-៦ (១0ច្បាប់)

៨-ឯកសារឧបសម្ពន្ធ B : ផែនទីគំរូ (សិក្ខាកាមម្នាក់១0ច្បាប់)

៩- ឯកសារឧបសម្ពន្ធ C : ករណីសិក្សា (១0ច្បាប់)

១០- ឯកសារទម្រង់ស្រាវជ្រាវ សំរាប់សិស្សថ្នាក់ទី៥-៦ (៥០ច្បាប់)

**VI. លំនាំ**

*១-ការប្រជុំជាមួយអ្នកគ្រប់គ្រងសាលារៀន បុគ្គលិកសាលារៀន មេភូមិ សហគមន៍ ព្រមទាំងតំណាងក្រុមប្រឹក្សាឃុំ*

អ្នកសម្របសម្រួលពន្យល់ពីគោលបំណងនៃការប្រជុំ រួចរៀបចំសិក្ខាកាម ជាក្រុមតូចៗរួចចែកក្រដាសរាមតូចទៅសិក្ខាកាម ដើម្បីសរសេរអំពីបញ្ហាកុមារដែលមិនបានចូលរៀន។ បន្ទាប់មកអ្នកសម្របសម្រួលប្រមូលចម្លើយរបស់សិក្ខាកាមមករៀបចំជាដើមឈើបញ្ហាដោយកំណត់បញ្ហាចម្បង (កុមារមិនបានចូលរៀន)។

- *ហេតុអ្វីបានជាកុមារនៅតាមភូមិមិនបានចុះឈ្មោះចូលរៀន ?*

<u>ចម្លើយ</u>

-កុមារកំព្រា

-កុមារពិការ

-កុមារដែលមានគ្រួសារក្រីក្រ

-កុមារដែលមានផ្ទះឆ្ងាយពីសាលារៀន

-កុមារដែលជាប់រវល់មើលប្អូននៅផ្ទះ

-ឪពុកម្តាយមិននាំកូនទៅចុះឈ្មោះចូលរៀន

-ឪពុកម្តាយផ្លាស់ប្តូរទីលំនៅតាមរយៈការងារ ។ល។

- អ្នកសម្របសម្រួលដឹកនាំសិក្ខាកាមរៀបចំបញ្ហាទាំងនោះជាដើមឈើបញ្ហា។ ប្រសិនបើគំនិតយោបល់របស់សិក្ខាកាមមិនបានបង្ហាញដូចចម្លើយខាងលើទេ អ្នកសម្របសម្រួលអាចជួយណែនាំបន្ថែម។
- អ្នកសម្របសម្រួលពន្យល់ទៀតថាដើម្បីដោះស្រាយលើបញ្ហាមិនបានចុះឈ្មោះចូលរៀនយើងត្រូវធ្វើការកំណត់ ចំពោះកុមារដែលមានសេចក្តីប្រថុយមិនបានចុះឈ្មោះចូលរៀន។ កុមារដែលមិនបានទៅសាលារៀនគឺមិនបានទទួលអត្ថប្រយោជន៍ ពីការអប់រំដែលាលារៀនផ្តល់អន្តរាគមន៍ដូចជា អាហារពេលព្រឹក អាហាររូបករណ៍សំរាប់សិស្សក្រីក្រ ការជួយឧបត្ថម្ភចំពោះសិស្សពិការ ។ល។
- អ្នកសម្របសម្រួលពន្យល់ទៀតថា យើងមានរបៀបច្រើនយ៉ាងដើម្បីកំណត់កុមារដែលប្រថុយមិនបានចុះឈ្មោះចូលរៀន ។

១. ពិនិត្យមើលឈ្មោះសិស្សដែលបានទទួលអាហារូបករណ៍កាលពីឆ្នាំមុន ។

២. ពិនិត្យមើលឈ្មោះសិស្សដែលបានចូលរួមក្នុងសកម្មភាពគេហកិច្ចកាលពីឆ្នាំមុន។

៣. ពិនិត្យមើលឈ្មោះសិស្សដែលបានអវត្តមានជាញឹកញាប់កាលពីឆ្នាំមុន។ អ្នកសម្របសម្រួលត្រូវពន្យល់ថាអវត្តមានជាញឹកញាប់ បាននយ័ថា សិស្សណាម្នាក់អវត្តមានចាប់ពី ៥ ដង ឬច្រើនជាង ៥ ដង ក្នុងរយៈពេល១ខែ ។

៤. ពិនិត្យមើលឈ្មោះសិស្សដែលមានអវត្តមានជាប់គ្នាយូរក្នុងឆ្នាំកន្លងមក ។ អ្នកសម្របសម្រួលពន្យល់ថា អវត្តមានជាប់គ្នាយូរមានន័យថា សិស្សអវត្តមាន ២០ថ្ងៃជាប់ៗគ្នា ឬច្រើន ជាងនេះ ។

៥. ពិនិត្យមើលឈ្មោះសិស្សដែលបោះបង់ការសិក្សាកាលពីឆ្នាំមុន ។ អ្នកសម្របសម្រួលត្រូវពន្យល់ថា សិស្សដែលបោះបង់ការសិក្សា គឺជាសិស្សដែលឈប់រៀនរហូត ហើយមិនដែលត្រឡប់មកចូលរៀននៅសាលាវិញទេ ។

៦. ចុះពិនិត្យមើលតាមផ្ទះដែលសិស្សរស់នៅ និង ពិនិត្យមើលថាតើនរណាដែលត្រូវចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សានេះ ។

• អ្នកសម្របសម្រួលត្រូវពន្យល់ថា នាយកសាលា និង គ្រូបន្ទុកថ្នាក់ត្រូវទទួលខុស ត្រូវចំពោះការប្រមូលទិន្នន័យនេះសម្រាប់ឆ្នាំសិក្សា ២០០៣-០៤ លើចំណុចទាំង៥ ដែលបាន រៀបរាប់ខាងលើ ។ គ្រូម្នាក់ៗត្រូវត្រួតពិនិត្យបញ្ជីវត្ត មាន សិស្សកាលពីឆ្នាំមុន បញ្ជីសិស្សដែលទទួលអាហារូបករណ៍ និង បញ្ជីឈ្មោះសិស្សដែលបានចូលរួមក្នុងសកម្មភាពគេហកិច្ច ព្រមទាំងស្រង់ឈ្មោះទាំងនេះដោយភ្ជាប់ជាមួយអាសយដ្ឋានរបស់ពួកគេផង( ក្រុម ភូមិ និង ឃុំ) ។ អ្នកសម្របសម្រួលត្រូវតាម ដាការងាររបស់គ្រូដើម្បីឱ្យដឹងច្បាស់ថាតើទិន្នន័យទាំងអស់អាចធ្វើទៅបានក្នុងរយៈពេល ១សប្តាហ៍ឬទេ ។

• អ្នកសម្របសម្រួលត្រូវពន្យល់ថា នៅសប្តាហ៍ទី២ខែវិច្ឆិកាសិស្សថ្នាក់ទី៥និងទី៦និងត្រូវបានធ្វើការស្រាវជ្រាវនៅក្នុងក្រុម ឬភូមិរបស់គេដែលមានកុមារអាយុចាប់ពី ៦ឆ្នាំទៅ១២ឆ្នាំដែលមិនបានចុះឈ្មោះចូលរៀន ។ ដើម្បីឱ្យសិស្សងាយស្រួលក្នុងការស្រាវជ្រាវ គ្រូថ្នាក់ទី៥និងទី៦ត្រូវបង្រៀនមេរៀននេះដល់សិស្សដល់សិស្សរបស់គេ។ អ្នកសម្របសម្រួលត្រូវផ្តល់ឱ្យគ្រូនូវឯកសារបង្រៀន ( ផែនការបង្រៀនសូមមើលឧបសម្ព័ន ក ) ហើយពិភាក្សាលើឯកសារនោះ ។

• អ្នកសម្របសម្រួលត្រូវពន្យល់ទៀតថា ព័ត៌មានដែលបានប្រមូលដោយគ្រូ និង លទ្ធផលនៃការស្រាវជ្រាវដោយសិស្សទាំងអស់ត្រូវបានបញ្ចូលទៅក្នុងផែនទីមួយដែលចង្អុលបង្ហាញអំពីកន្លែងដែលសិស្សមានសេចក្តីប្រថុយមិនបានចុះឈ្មោះចូលរៀន។ ប្រសិនបើយើងដឹងច្បាស់ថា កុមារណាដែលមិនបានចុះឈ្មោះ និង គេរស់នៅឯណានោះ យើងត្រូវចាត់វិធានការដើម្បីជួយកុមារទាំងនោះឱ្យបានចូលរៀន។ អ្នកសម្របសម្រួលត្រូវរៀបចំការប្រជុំក្នុងរយៈពេល១សប្តាហ៍ដើម្បីបំពេញផែនទីពីសិស្សដែលមានសេចក្តីប្រថុយ មិនបាន ចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សាខាងមុខ ។

២-ការរៀបចំផែនទីជាមួយអ្នកគ្រប់គ្រងសាលាបុគ្គលិកសិក្សា មេភូមិ សហគមន៍ តំណាងក្រុមប្រឹក្សាឃុំ ព្រមទាំងសិស្សថ្នាក់ទី៥ និងទី៦ និង ការកំណត់អន្តរាគមន៍

• អ្នកសម្របសម្រួលត្រូវពន្យល់លថាគោលបំណងនៃការប្រជុំនេះ ដើម្បីបង្កើតផែនទីបង្ហាញអំពីទីកន្លែងរបស់កុមារដែលមិនបានចុះឈ្មោះចូលរៀន ។ ម្យ៉ាងទៀតការពិភាក្សាអាចកំណត់ពីអន្តរាគមនផ្សេងៗ ដើម្បីជួយកុមារឱ្យចូលរៀន ។

• អ្នកសម្របសម្រួលត្រូវរៀបចំសិក្ខាកាមជាក្រុមតូចៗទៅតាមភូមិ រួចចែកហ្វឺតក្រដាស់ផ្ទាំងធំទៅក្រុមនីមួយៗ ឱ្យរៀបចំផែនទីដោយគូរបង្ហាញអំពីហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា សំណង់អាគារ ប្រភពទឹក និង ផ្លូវផ្សេងៗ ។

**ចំណាំ :** *១ សង់ទីម៉ែត្រនៅលើផែនទីស្មើនឹង១០ម៉ែត្រលេចំងាយជាក់ស្តែង ។*

• អ្នកគ្រប់គ្រងសាលា ព្រមទាំងបុគ្គលិកសិក្សា មេភូមិ សហគមន៍ តំណាងក្រុមប្រឹក្សាឃុំ និង សិស្សថ្នាក់ទី៥-៦ ត្រូវបង្ហាញព័ត៌មានជាមួយគ្នាដើម្បីកំណត់ពីទីតាំងផ្ទះរបស់សិស្សដែលមិនបានចុះឈ្មោះចូលរៀននៅលើផែនទី ។នៅក្នុងផែនទីត្រូវ បញ្ចូលកំនត់សំគាល់ដើម្បីបញ្ជាក់ពីចំងាយនិង បញ្ជាក់ពីមូលហេតុ ដែលកុមារមិនបានទៅរៀន (កុមារក្រីក្រ កុមារពិការ កុមារកំព្រាឳពុកម្តាយមិនបានបញ្ជូនកូនឱ្យទៅរៀន ...) ។ សូមមើលឧបសម្ពន្ធ ខ **ផែនទីគំរូ** ។

• ក្រុមនីមួយៗត្រូវបង្ហាញអំពីផែនទីរបស់គេ ចំណែកក្រុមផ្សេងទៀតចូលរួមវិភាគលើការពន្យល់បង្ហាញរបស់គេ រួចសួរសំណួរប្រសិនបើមានចម្ងល់ ។ សិក្ខាកាមម្នាក់ត្រូវស្រង់យកនូវព័ត៌មានពីផែនទីផ្សេងៗទាំងនោះ ដើម្បីរៀនចំជាផែនទីតែមួយដោយផ្តោតទៅលើក្រុមសិស្សដែលមាននៅក្នុងមូលដ្ឋាន ។

• អ្នកសម្របសម្រួលចែកករណីសិក្សាឧបសម្ពន្ធ គទៅតាមក្រុមរួចសួរក្រុមនីមួយៗឱ្យកំណត់ពីអន្តរាគមន៍ដែលសមស្របដើម្បីដោះស្រាយបញ្ហា ។

• ក្រុមនីមួយៗត្រូវបង្ហាញពីគំនិតយោបល់របស់គេនូវអ្វីដែលគេបានពិភាក្សា ថាតើអន្តរាគមន៍ដែលបានកំណត់នោះសមស្របឬទេ ។

*អន្តរាគមន៍មួយចំនួនត្រូវបានបង្ហាញដូចខាងក្រោម :*

ក. កុមារដែលស្ថិតក្នុងគ្រួសារក្រីក្រ ឬ កំព្រាអាចដាក់ពាក្យសុំអាហារូបករណ៍ ។ ដូចនេះគឺជួយបន្ធូរជីវភាពឳពុកម្តាយក្នុងការទិញប៊ិច សៀវភៅ និង សំលៀកបំពាក់ ។

ខ.កុមារីដែលរៀននៅថ្នាក់ទី៥ និងទី៦ អាចចូលរួមក្នុងកម្មវិធីគេហកិច្ច ដែលគេអាចយកចំណេះដឹងដែលបានរៀនពីកម្មវិធី ទៅប្រកបរបរចិញ្ចឹមជីវិតប្រចាំគ្រួសារ ។

គ. សិស្សអាចចូលរួមក្នុងកម្មវិធីស្រែពិសោធន៍ ដើម្បីស្វែងយល់ពីរបៀបបង្កបង្កើនផលស្រូវប្រកបដោយទិន្នផលខ្ពស់ ។

ឃ. សិស្សពិការអាចទទួលជំនួយតាមរយៈការវះកាត់បន្តិចបន្តួច ការព្យាបាលភ្នែក និង ត្រចៀក ។

ង. សិស្សពិការមានឱកាសបានចូលរៀនតាមរយៈសកម្មភាពកុមារជួយកុមារ ។

ច. សិស្សរៀនយឺតអាចទទួលនូវកម្មវិធីបង្រៀនបន្ថែមនៅក្នុងបណ្ណាល័យ ។

ឆ. សិស្សអាចូលរួមក្នុងកម្មវិធីបំណិនជីវិត ដែលគេអាចយកចំណេះដឹងដែលគេបានរៀនពីកម្មវិធីទៅប្រកបរបរចិញ្ចឹមជីវិត ។

• អ្នកសម្របសម្រួលត្រូវពន្យល់ថា និង គ្រូទាំងអស់ត្រូវតាមដានទៅលើបញ្ហាទាំងឡាយណា ដែលបានកំណត់នៅក្នុងផែនទីសិក្សា ។អ្នកគ្រប់គ្រងសាលារៀនព្រមទាំងបុគ្គលិកសាលានិងសហគមន៍ត្រូវសហការគ្នាដើម្បីកំណត់ការធ្វើអន្តរាគមន៍ឱ្យបានសមស្របដែលអាចយក ទៅអនុវត្តក្នុងការជួយកុមារឱ្យបានចុះឈ្មោះចូលរៀន ។

☆ ចំពោះអាហារូបករណ៍សិស្សក្រីក្រ អាចធ្វើអន្តរាគមន៍តាមរយៈថវិកាត្រៀមបំរុងរបស់អាហារូបករណ៍ ថវិកា OPTION ឬពិភាក្សាសុំយោបល់ពីបុគ្គលិកទទួលខុសត្រូវរបស់ខេប ។

# ឧបសម្ព័ន្ធ ក ៖ ផែនការបង្រៀនសម្រាប់គ្រូថ្នាក់ទី៥ និង ទី៦ ស្តីអំពីឧបករណ៍ស្រាវជ្រាវនៅផ្ទះ

## I.សេចក្តីផ្តើម

- មានកុមារជាច្រើននាក់ដែលមិនបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ។ នេះគឺជាបញ្ហា ដែលកុមារ ងាយរងគ្រោះមួយចំនួនប្រឈមមុខដូចជាកុមារកំព្រា កុមារពិការ កុមារដែលមានគ្រួសារក្រីក្រ និង កុមារដែលមានទីលំនៅឆ្ងាយពីសាលារៀន។ អង្គការខេប (KAPE) បានព្យាយាមដោះស្រាយបញ្ហាទាំងនេះដោយផ្តល់ជាអាហារូបករណ៍សម្រាប់សិស្សក្រីក្រ។ ទោះបីជាបែបនេះក៏ដោយសាលារៀនក៏ត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីកុមារដែលមានសេចក្តីប្រថុយមិនបានចុះឈ្មោះចូលរៀន។ មានកុមារ ជាច្រើនបានស្គាល់កុមារផ្សេងៗទៀតដែលមានវ័យស្របាលគ្នាហើយមិនបានចុះឈ្មោះចូលរៀន ។ ដូច្នេះកុមារទាំងអស់នេះគឺជាប្រភពមួយដ៏សំខាន់ ដើម្បីទទួលព័ត៌មានអំពីសិស្សដែលគ្រប់អាយុមិនបានចុះឈ្មោះចូលរៀន ។ ដើម្បីរៀបចំព័ត៌មាននេះ សិស្ស ថ្នាក់ទី៥ និង ទី៦ ត្រូវសិក្សាអំពី ឧបករណ៍ស្រាវជ្រាវនៅតាមផ្ទះជាមួយគ្រួសារទាំងឡាយណា ដែលពុំបានបញ្ជូនកូនឱ្យ ទៅរៀន ។

## II.គោលបំណង

- សិស្សថ្នាក់ទី៥ និង ទី៦ អាចបំពេញឧបករណ៍ស្រាវជ្រាវនៅតាមផ្ទះបានដោយខ្លួនឯង ។

## III.លំនាំ

- គ្រូត្រូវពន្យល់ថា កុមារម្នាក់ៗមានសិទ្ធិនឹងទទួលការអប់រំស្មើៗគ្នា ។ ប៉ុន្តែមានកុមារជាច្រើននាក់ ដែលមិនបានចុះឈ្មោះចូលរៀន ។ នេះជាបញ្ហាដែលធ្វើឱ្យកុមារងាយរងគ្រោះ ជាពិសេសចំពោះកុមារពិការ កុមារកំព្រា និង កុមារដែលមានគ្រួសារក្រីក្រ ។
- គ្រូរៀបចំសិស្សជាក្រុមតូច រួចសួរសំណួរដូចខាងក្រោម ៖

✶ *តើមានមូលហេតុអ្វីខ្លះដែលធ្វើឱ្យមិត្តភក្តិរបស់ប្អូនមិនបានមកសាលារៀន ?*

<u>ចម្លើយ</u>

- ឪពុកម្តាយទុកកូនឱ្យជួយធ្វើការផ្ទះ
- មើលប្អូនតូចៗ
- គ្មានថវិកាសម្រាប់ទិញសម្ភារសិក្សា ( ប៊ិច សៀវភៅ សំលៀកបំពាក់ )
- កុមារដែលពិការមានអារម្មណ៍អៀនខ្មាស់មិនចង់មករៀន
- កុមារខ្លះយល់ថា ខ្លួនធំពេកមានភាពខ្មាស់អៀនក្នុងការមករៀន ។

- គ្រូសួរក្រុមនីមួយៗឱ្យបញ្ជាក់ពីគំនិតយោបល់របស់គេថាតើគំនិតទាំងនោះសមស្របតាមចម្លើយខាងលើដែរឬទេ? បើសិនពុំបានបង្ហាញដូចចម្លើយខាងលើនោះទេគ្រូអាចបញ្ជាក់បន្ថែម ។

- គ្រូពន្យល់ទៀតថា សាលារៀនអាចរៀបចំសកម្មភាពជាច្រើន ដើម្បីជួយជំរុញ និង លើកទឹកចិត្តកុមារឱ្យមករៀន

បន្ទាប់មកផ្តល់ឧទាហរណ៍ដូចខាងក្រោម :

ក.កុមារដែលមានគ្រួសារក្រីក្រអាចដាក់ពាក្យសុំអាហារូបករណ៍ពីសាលារៀន កម្មវិធីនេះអាចជួយបន្ធូរភាពឪពុកម្តាយក្នុងការទិញសម្ភារ សិក្សា និង សំលៀកបំពាក់ដល់កូនរបស់ខ្លួន ។

ខ.កុមារីដែលរៀននៅថ្នាក់ទី៥ និង ទី៦ អាចចូលរួមក្នុងកម្មវិធីគេហកិច្ច ដែលគេអាចយកចំណេះដែលគេបានរៀនពីកម្មវិធីនៅក្នុងសាលារៀនទៅប្រកបរបរចិញ្ចឹមជីវិតប្រចាំគ្រួសារ ។

គ. សិស្សអាចចូលរួមក្នុងកម្មវិធីស្រែពិសោធន៍ ដើម្បីស្វែងយល់ពីរបៀបបង្កបង្កើនផលស្រូវប្រកបដោយទិន្នផលខ្ពស់ ។

ឃ. សិស្សពិការអាចទទួលជំនួយ តាមរយៈការវះកាត់បន្តិចបន្តួច ការព្យាបាលភ្នែក និង ការព្យាបាលត្រចៀក ។

ង. សិស្សពិការមានឱកាសបានចូលរៀនតាមរយៈសកម្មភាពកុមារជួយកុមារ ។

ច. សិស្សរៀនយឺតបានទទួលនូវកម្មវិធីបង្រៀនបន្ថែម តាមរយៈថ្នាក់កែតម្រូវ និង សកម្មភាពបង្រៀនបន្ថែមនៅក្នុងបណ្ណាល័យ ។

- គ្រូត្រូវពន្យល់ទៀតថា នៅពេលដែលកុមារគ្រប់អាយុបានចុះឈ្មោះចូលរៀន អ្នកគ្រប់គ្រងសាលា ត្រូវព្យាយាមជួយដោះស្រាយនូវបញ្ហាទាំងឡាយណាដែលគេកំពុងប្រឈមមុខ ។ ម្យ៉ាងទៀតប្រសិនបើយើងដឹងច្បាស់ថា កុមារណាដែលមិនបានចុះឈ្មោះ ហើយនៅកន្លែងណានោះ យើងអាចធ្វើអន្តរាគមន៍ដើម្បីជួយកុមារទាំងនោះបាន ។

- គ្រូពន្យល់ថាសាលារៀនត្រូវការការគាំទ្រពីសិស្សថ្នាក់ទី៥ និង ទី៦ដើម្បីកំណត់ផ្ទះរបស់កុមារដែលមិនបានចុះឈ្មោះចូលរៀននៅក្នុងឆ្នាំ។គ្រូត្រូវចែកឧបករណ៍ស្រាវជ្រាវនៅផ្ទះ(មើលប្រអប់លេខ ១ ) ខាងក្រោម រួចពិភាក្សាទៅលើខ្លឹមសារក្នុងឧបករណ៍នោះជាមួយសិស្ស ។ គ្រូត្រូវរៀបចំសិស្សជាគូរ ។ បន្ទាប់មកចែកករណីសិក្សាទៅគូរនីមួយៗឱ្យគេអាន ។ គ្រូអាចសួរសិស្សនៅពេលដែលគេអានឧបករណ៍ស្រាវជ្រាវ រួច ពន្យល់បន្ថែមបើសិនជាសិស្សមានសំណួរ ។

- គ្រូបង្ហាញផែនទីឱ្យសិស្សសង្កេត(មើលឧបសម្ពន្ធ័ខ) រួចពន្យល់ពីរបៀបបង្កើតមាត្រដ្ឋាននិងកំណត់គាល់ផ្សេងៗដែលមាននៅក្នុងផែនទី។ បន្ទាប់មកត្រូវរៀបចំសិស្សជាក្រុម រួចឱ្យគេចេញទៅក្រៅដើម្បីរៀបចំផែនទីមួយនៅលើដី បង្ហាញទីតាំងនៅពទ្ធ័ជុំវិញសាលារៀនរបស់គេដោយប្រើមាត្រដ្ឋាន១សង់ទីម៉ែត្រនៅលើផែនទីស្មើនឹង១០ម៉ែត្រលើចំងាយជាក់ស្តែង។ ក្នុងផែនទីគួរតែបញ្ចូលពីហេដ្ឋារចនាសម្ពន្ធ័សំខាន់ផ្សេងៗដូចជា មណ្ឌលសុខភាព សាលារៀន ផ្លូវ...។

- គ្រូដើរពិនិត្យមើលក្រុមសិស្សនីមួយៗ និង ជួយណែនាំបន្ថែម ។

- គ្រូពន្យល់ថាសិស្សអាចប្រើឧបករណ៍ស្រាវជ្រាវជាលក្ខណៈប្រឡងប្រណាំង ។ បើសិនសិស្សណាអាចស្រាវជ្រាវរកសិស្ស ឬ កុមារដែលមិនបានចូលរៀនបានច្រើនជាងគេគឺជាអ្នកឈ្នះ ។ ចំពោះអ្នកឈ្នះលេខ ១ លេខ ២ និង លេខ ៣ អាចទទួលរង្វាន់លើកទឹកចិត្តពីសាលារៀន។ គ្រូពន្យល់ថាសិស្សទាំងអស់មានពេលជិត១សប្តាហ៍ដើម្បីបំពេញឧបករណ៍ស្រាវជ្រាវរបស់គេ។ បន្ទាប់ពីរយៈពេល ១ សប្តាហ៍គ្រូត្រូវរៀបចំប្រជុំមួយទៀតដើម្បីបញ្ចូលព័ត៌មានទាំងអស់នៅក្នុងផែនទីសិក្សា ។

## ប្រអប់លេខ១: ទម្រង់សំរាប់ស្រាវជ្រាវសិស្សនៅតាមផ្ទះ

ព្យាយាមស្រាវជ្រាវពត៌មាននៅក្នុងក្រុមរបស់ប្អូនជាមួយសិស្សដែលមានអាយុពី ៦-១២ឆ្នាំ ដែលមិនបានចូលរៀនក្នុងឆ្នាំសិក្សា ២០០៤-០៥ ប្អូនសួរសំណួរទៅគេនិងក្រុមគ្រួសារ គេដូចខាងក្រោម:

១- អាសយដ្ឋាន:.........................................................................................................................................

-ឈ្មោះក្រុម:.........................................................................................................................................

-ឈ្មោះភូមិ :.........................................................................................................................................

-ឈ្មោះឃុំ: .........................................................................................................................................

២- ឈ្មោះនិងអាយុកុមារដែលមិនបានចូលរៀនក្នុងឆ្នាំសិក្សា ២០០៤-០៥

-ឈ្មោះ...................................អាយុ:......................ភេទ :..........................

- ឈ្មោះ...................................អាយុ:......................ភេទ :..........................

-ឈ្មោះ...................................អាយុ:......................ភេទ :..........................

-ឈ្មោះ...................................អាយុ:......................ភេទ :..........................

-ឈ្មោះ...................................អាយុ:......................ភេទ :..........................

៣- តើកុមារទាំងនោះមានឪពុកម្តាយឬទេ ? (ប្រើសញ្ញា ✓ ក្នុងប្រអប់)

-មានឪពុកម្តាយ ☐

-មានតែឪពុក ឬម្តាយ☐

-គ្មានឪពុកម្តាយ☐

៤- តើក្នុងចំណោមកុមារទាំងនេះមានកុមារពិការឬទេ? (ភ្នែក, ត្រចៀក, ពិការដៃ ជើង ពិការអវយវៈណាមួយ)

បាទ/ ចាស (គូសរង្វង់មូលត្រង់ចម្លើយត្រឹមត្រូវ)

-បើមានតើកុមារដែលពិការនោះឈ្មោះអ្វី?.........................................................................................................

-តើពិការអ្វី? .........................................................................................................................................

៥- តើអាណាព្យាបាលកុមារនេះអាចមានលទ្ធភាពទិញប៊ិច សៀវភៅ សំលៀកបំពាក់សំរាប់កូនខ្លួនបានឬទេ ?

- បាទ : ឪពុកម្តាយមានលទ្ធភាពទិញសម្ភារសិក្សាឱ្យកូនពីព្រោះមានជីវភាពធូរធា
- ទេ : ឪពុកម្តាយមានលទ្ធភាពទិញសម្ភារបានខ្លះៗ ពីព្រោះមានជីវភាពមធ្យម
- ទេ : ឪពុកម្តាយមានលទ្ធភាពទិញសម្ភារបានខ្លះៗ ពីព្រោះមានជីវភាពក្រីក្រ

សូមគូសផែនទីបង្ហាញអំពីក្រុមសិស្សនេះ ព្រមទាំងបញ្ចូលហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា មណ្ឌលសុខភាព, សាលារៀនផ្លូវថ្នល់ផ្សេងៗ នៅផ្នែកខាងក្រោយនៃឧបករណ៍ស្រាវជ្រាវដោយកំណត់នៅក្នុងផែនទីអំពីទីតាំងផ្ទះរបស់កុមារនេះ។

**<u>សំគាល់:</u>** 1cm នៅលើផែនទីស្មើនឹង 10m លើចម្ងាយពិតប្រាកដ។

# ឧបសម្ព័ន្ធ : ខ



## ឧបសម្ព័ន្ធគ : **ករណីសិក្សា**

គ្រួសាររបស់ **ភាព** រស់នៅក្នុងផ្ទះដ៏តូចមួយក្នុងក្រុមទី៥ ក្នុងភូមិត្រពាំងអំពិល ឃុំជ្រៃវៀន ស្រុកព្រៃឈរ ស្ថិតនៅចម្ងាយប្រមាណ ២គីឡូម៉ែត្រពីសាលារៀន។ គ្រួសាររបស់ **ភាព** មានសមាជិក១០នាក់ ហើយមានតែកូនប្រុសបង ២នាក់ប៉ុណ្ណោះដែលបានទៅរៀន ។ចំណែកកូនពីរនាក់ទៀតឈ្មោះសុខានិងតារាដែលមានអាយុ៩ឆ្នាំនិង១១ឆ្នាំ មិនដែលបានចុះឈ្មោះចូលរៀនទេ ។ចំពោះបងស្រីរបស់គេឈ្មោះសុផាអាយុ១៣ឆ្នាំបាន បោះបង់ចោលការសិក្សានៅថ្នាក់ទី៥ថ្មីៗនេះ ។ តាមពិតនាងជាសិស្សចូលចិត្តរៀនសូត្រខ្លាំងណាស់ហើយថែមទាំងរៀនបានពូកែទៀតផង ។

ប៉ុន្តែឥឡូវនេះឪពុកម្តាយរបស់នាងឈប់ឱ្យនាងទៅរៀនទៀតហើយ ព្រោះត្រូវនៅជួយរកប្រាក់ខ្លះសម្រាប់គ្រួសារ ។ ចំណែកឯប្អូនប្រុសរបស់នាងវិញ ឈ្មោះ សុខណា បានចូលរៀននៅថ្នាក់ទី១ កាលពីឆ្នាំទៅ ប៉ុន្តែឥឡូវគេបានបោះបង់ចោលការសិក្សា ដោយសារតែភ្នែករបស់គេមើលមិនច្បាស់ ។ ជាលទ្ធផលធ្វើឱ្យសុខណារៀនមិនទាន់ គេគ្រប់មុខវិជ្ជា ។

ចំពោះតារាវិញជាក្មេងដ៏ឈ្លាសវៃមួយ ប៉ុន្តែវាបានបដិសេដមិនទៅរៀន ពីព្រោះវាមានអារម្មណ៍ខ្មាស់អៀនដោយសារគេមានពងកោប។ ចិត្តរបស់គេក៏ចង់ទៅរៀនណាស់ តែដោយសារបញ្ហានេះហើយទើបគេបដិសេធមិនព្រមទៅរៀន។ បងស្រីវាឈ្មោះសុខាក៏ដូចចង់ទៅរៀនដែរ ប៉ុន្តែដោយសារធ្វើស្រូវពុំបានទិន្នផលល្អ ឪពុកម្តាយពុំមានលុយគ្រប់គ្រាន់ ។

សំណួរ : តើអ្នកគ្រប់គ្រងសាលា និង ប្អូន ត្រូវធ្វើដូចម្តេចខ្លះ ដើម្បីលើកទឹកចិត្តឪពុកម្តាយរបស់ភាពឱ្យបញ្ជូនកូនទាំងអស់បានទៅសាលារៀន ?